ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥១ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋនៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាមួយបញ្ជាការដ្ឋានធ័ពរថក្រោះ ACO

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យដោះស្រាយទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋនៅភូមិសំបូរ ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាមួយបញ្ជាការដ្ឋានកងទ័ពរថក្រោះ ACO នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម :



www.pheakdeylaw.com

១- ឯកឧត្តម **នុត សានាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២- ឯកឧត្តម **ទីម ជាសោភ័ណ** អគ្គនាយក នៃអគ្គនាយកដ្ឋានអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច អនុប្រធាន

៣- ឯកឧត្តម **កុល វិរក្ស** អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល នៃក្រសួងមហាផ្ទៃ អនុប្រធាន

៤- ឯកឧត្តមឧត្តមសេនីយ៍ ទោ **ឈឹង នរិន្ទ្រ** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ និងជានាយ ក នៃនាយកដ្ឋានវិស្វកម្ម នៃក្រសួងការពារជាតិ អនុប្រធាន

៥- ឯកឧត្តម **ខូច សារុន** អភិ បាលរងខេត្តកំពង់ស្ពឺ អនុប្រធាន

៦- លោក **ឡូ ផល្លា** អនុប្រធានអធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៧- លោក **នេ ប៊ុនធឿន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៨- លោក **ខេព មាន** អភិបាលស្រុកភ្នំស្រួច សមាជិក

៩- លោក **ឈិម សុផល** មន្ត្រីការិយាល័យផែនការក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ច :

- ចុះពិនិត្យ និង ស្រាវជ្រាវពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ៣១គ្រួសារ នៅភូមិសំបូរ ឃុំតាំងស្យា ស្រុកភ្នំស្រួច ដែលប្តឹងតវ៉ាជាមួយបញ្ជាការដ្ឋានទ័ពរំដោះក្រោះ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។
- ធ្វើការសំរបសំរួលរវាងភាគីទាំងពីរអោយមានការស្រុះស្រួលគ្នាប្រសិនបើអាចធ្វើបាន។ ក្នុងករណីមិនអាចសំរុះសំរួលគ្នាបាន ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការស្រាវជ្រាវ និង លើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ៣ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញអ្នកពាក់ព័ន្ធនៅមូលដ្ឋាន រួមទាំងអង្គភាព មន្ទីរ ឬ ស្ថាប័នពាក់ព័ន្ធ មកបំភ្លឺ និង ផ្តល់ឯកសារពាក់ព័ន្ធក្នុងក្របខណ្ឌសមត្ថកិច្ច និង ភារកិច្ច ដូចបានចែងក្នុងប្រការ២ ខាងលើ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលខេត្តកំពង់ស្ពឺ និង ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុង ប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

Royal Gov't Decision

www.pheakdeylaw.com